ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខ: ១១៥ ...

រាជធានីភ្នំពេញ , ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៨

លិខិតចូល

ថ្ងៃទី១៩ ... ខែមិថុនា ឆ្នាំ២០០៨

# ប្រកាស

ស្តីពី

## ការបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ ប្រាសាទបុរាណ រមណីយដ្ឋានបុរាណវិទ្យា-បុរេប្រវត្តិវិទ្យា នៃព្រះរាជាណាចក្រកម្ពុជា

---

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៩៨ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការអនុវត្តកិច្ចការពារ បេតិកភណ្ឌវប្បធម៌
- បានឃើញអនុក្រឹត្យលេខ២៤អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។
- បានឃើញសារាចរណែនាំលេខ០៥ ស.រ.ណ.ន ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០២ ស្តីពីបំរាមធ្វើអាជីវកម្មរុករក និងបំផ្លាញវត្ថុបុរាណ របស់រាជរដ្ឋាភិបាលកម្ពុជា ។
- យោងតាមការចាំបាច់របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

# សម្រេច

**ប្រការ១ ..**

ត្រូវបានចុះក្នុងបញ្ជីសារពើភណ្ឌ បេតិកភណ្ឌវប្បធម៌ជាតិ នូវប្រាសាទបុរាណ រមណីយដ្ឋានបុរាណវិទ្យា-បុរេប្រវត្តិវិទ្យា ដែលមានទីតាំងក្នុងភូមិសាស្ត្រ ខេត្តកំពតបច្ចុប្បន្ន ចំនួន៩៦ (កៅសិបប្រាំមួយ) កន្លែង ។

**ប្រការ២ .-**

ឈ្មោះ អាសយដ្ឋាន នៃទីតាំង ប្រាសាទបុរាណ រមណីយដ្ឋានបុរាណវិទ្យា បុរេប្រវត្តិវិទ្យា ដែលបានកំណត់ក្នុងប្រការ១ មានចែងក្នុងឧបសម្ព័ន្ធ នៃប្រកាសនេះ ។

**ប្រការ៣ .-**

ប្រាសាទបុរាណ រមណីយដ្ឋានបុរាណវិទ្យា-បុរេប្រវត្តិវិទ្យា ទាំងអស់ដែលបាន ឬមិនទាន់ បានចុះក្នុងបញ្ជីសារពើភណ្ឌ បេតិកភណ្ឌវប្បធម៌ជាតិក្តី ត្រូវចាត់ចូលក្នុងសម្បត្តិសាធារណៈរបស់រដ្ឋ ។

**ប្រការ៤ .-**

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ គឺជានីតិបុគ្គលសាធារណៈ ដែលមានសមត្ថកិច្ចធ្វើសំណើសុំវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ និងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ពីរដ្ឋបាលសុរិយោដីនូវទីតាំងប្រាសាទបុរាណ រមណីយដ្ឋានបុរាណវិទ្យា -បុរេប្រវត្តិវិទ្យាទាំងអស់ដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះជាទ្រព្យសម្បត្តិសាធារណៈ ។

**ប្រការ៥ .-**

ដែនការពារប្រាសាទបុរាណ រមណីយដ្ឋានបុរាណវិទ្យា-បុរេប្រវត្តិវិទ្យា ត្រូវកំណត់ក្នុងប្រកាស១ដោយឡែក ។

**ប្រការ៦ .-**

នាយកខុទ្ទកាល័យ អធិការ សវនករ អគ្គនាយកបេតិកភណ្ឌ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពត មានភារកិច្ចអនុវត្តប្រកាសនេះ តាមមុខងាររៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**ទើង សិរីវុឌ្ឍ**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់ខេត្ត ក្រុង
- រាជកិច្ច
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

## តារាងឧបសម្ព័ន្ធ

### បញ្ជីឈ្មោះប្រាសាទបុរាណ-រមណីយដ្ឋានបុរាណវិទ្យា-បុរេប្រវត្តិវិទ្យា

### ក្នុងភូមិសាស្ត្រខេត្តកំពត ដែលត្រូវបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ

តាមប្រកាសលេខ..១០៩.....ប្រក.វវស. ចុះថ្ងៃទី..០៩.....ខែ..មិនា..ឆ្នាំ ២០០៨

| ល.រ | ឈ្មោះ | លក្ខណៈពិសេស | ផ្សេងៗ |
|---|---|---|---|
| I- | ស្រុកអង្គរជ័យ | | |
| 1 | រថបល្ល័ង្គ | ទួល | |
| 2 | ទួលអង្គត្រពាំងខ្សង | ទួល | |
| 3 | ទួលអង្គត្រពាំងធំ | ទួល | |
| 4 | វត្តអង្គឈូក | វត្ត | |
| 5 | ទួលអង្គលាំង | ទួល | |
| 6 | ទួលអង្គតាសោម | ទួល | |
| 7 | ទួលអង្គជំនីក | ទួល | |
| 8 | ទួលអង្គកប់ខ្ញុំ | ទួល | |
| 9 | ទួលអង្គស្វដា | ទួល | |
| 10 | ទួលអង្គភ្នំតូច | ទួល | |
| 11 | ទួលអង្គរំដួល | ទួល | |
| 12 | ទួលស្រះប្រឹង | ទួល | |
| 13 | វត្តអង្គរជ័យ | វត្ត | |
| 14 | វត្តអង្គរទេព | វត្ត | |

D:\L-Reny 2008\31-04-06\Prakas 98 Kompot.xls

| | | |
|---|---|---|
| 15 | វត្តទន្លេលៀម | វត្ត |
| 16 | ទួលអង្គតាលួង | ទួល |
| 17 | ទួលអង្គមួយ | ទួល |
| 18 | ទួលអង្គបី | ទួល |
| 19 | វត្តម្រោម | វត្ត |
| 20 | ព្រះឱង្ការ | ទួល |
| 21 | ទួលអង្គតារត្ន | ទួល |
| 22 | ទួលអង្គ | ទួល |
| 23 | ទួលអង្គតាជុំ | ទួល |
| 24 | ទួលអង្គប្រាសាទ | ទួល |
| 25 | ទួលអង្គជ្រុះស្លាន់ | ទួល |
| 26 | វត្តត្រពាំងខ្វា | វត្ត |
| 27 | ទួលអង្គ | ទួល |
| 28 | វត្តរលាំង | វត្ត |
| 29 | ទួលអង្គនាល | ទួល |
| 30 | ទួលអង្គទោះ, អង្គអន្ទោះ | ទួល |
| 31 | ទួលអង្គខ្មែរ | ទួល |
| 32 | ទួលអង្គរកា | ទួល |
| 33 | ទួលយាយនិប | ទួល |
| 34 | អង្គកាប់ទូក | ទួល |
| 35 | ត្រពាំងអណ្តូង | ទួល |
| 36 | វត្តអង្គស្លុក | វត្ត |
| 37 | គោកស្រងែ | ទួល |
| 38 | ទួលអង្គវត្តិ | ទួល |
| 39 | វត្តតានី | វត្ត |

| | | |
|---|---|---|
| II- | ស្រុកបន្ទាយមាស | |
| 40 | ទួលក្រាំងបន្ទាយ | ទួល |
| 41 | វត្តសំរោង | វត្ត |
| 42 | វត្តក្រាំងដូង | វត្ត |
| 43 | ទួលក្តីមាន | ទួល |
| 44 | ទួលវត្តព្រះ | ទួល |
| 45 | ទួលអង្គ | ទួល |
| 46 | ប្រាសាទភ្នំទទឹង | ប្រាសាទ |
| 47 | ទួលអង្គ | ទួល |
| III- | ស្រុកឈូក | |
| 48 | កោះអង្គ | ទួល |
| 49 | ទួលពោធិ៍ដុះ | ទួល |
| 50 | ទួលអង្គ | ទួល |
| 51 | អង្គប្រៀប | ទួល |
| 52 | អង្គប្រង់ | ទួល |
| 53 | វត្តអង្គទួល | វត្ត |
| 54 | វត្តអង្គស្វាយ | វត្ត |
| 55 | ទួលអង្គជ្រៃ | ទួល |
| 56 | ទួលអង្គ្រោង | ទួល |
| 57 | ទួលអង្គឈើទាល | ទួល |
| 58 | ទួលអង្គធំ | ទួល |
| 59 | ប្រាសាទភ្នំថ្មពួក | ប្រាសាទ |
| 60 | ទួលខ្លារ | ទួល |
| 61 | ទួលល្វ | ទួល |

| | | | |
|---|---|---|---|
| IV- | ស្រុកចងទង់ | | |
| 62 | ទួលប្រាសាទ | ទួល | |
| 63 | ទួលអង្គតាម៉ឹង | ទួល | |
| 64 | ទួលអង្គពូក | ទួល | |
| 65 | ទួលអង្គត្រពាំងចក | ទួល | |
| 66 | ទួលអង្គមោក | ទួល | |
| 67 | ភ្នំល្អាង | ភ្នំ | |
| 68 | ទួលអង្គប្រាង្គ | ទួល | |
| V- | ស្រុកកំពង់ត្រាច | | |
| 69 | ទួលដាស់ស្គរ | ទួល | |
| 70 | ទួលភូមិព្រៃទប់ | ទួល | |
| 71 | ទួលភូមិកោះចំការ | ទួល | |
| 72 | ភូមិស្វាយផ្អែម | ទួល | |
| 73 | ទួលភូមិអូរពពូល | ទួល | |
| 74 | ទួលភូមិកេស | ទួល | |
| 75 | អង្គភ្នំតូច | ទួល | |
| 76 | វត្តដូនពេញ | វត្ត | |
| 77 | ភ្នំកំពង់ត្រាច | ភ្នំ | |
| 78 | ប្រាសាទភ្នំខ្យង | ប្រាសាទ | |
| 79 | ភ្នំប្រាសាទ | ប្រាសាទ | |
| 80 | ទួលភូមិបង់បក់ | ទួល | |
| 81 | ទួលច្រនៀងទេ | ទួល | |
| 82 | ទួលភូមិរបងក្រាស់ | ទួល | |
| 83 | ទួលអង្គតាបែន | ទួល | |
| 84 | ទួលអង្គតាជ័យ | ទួល | |
| 85 | វត្តភូមិកោះស្លាក | វត្ត | |
| 86 | ទួលប្រាសាទ | ទួល | |
| 87 | ទួលភូមិកោះត្រាច | ទួល | |

| | | |
|---|---|---|
| VI- | ស្រុកកំពត | |
| 88 | ត្រពាំងធំ | ទួល |
| 89 | វត្តអង្គសិរីសោភា | វត្ត |
| 90 | ទួលអង្គរុន | ទួល |
| 91 | វត្តអង្គធំ | វត្ត |
| 92 | វត្តភ្នំស | វត្ត |
| 93 | ប្រាសាទភ្នំឈ្លោក | ប្រាសាទ |
| 94 | វត្តអង្គស្លុក | វត្ត |
| 95 | ប្រាសាទក្បាលរមាស | ប្រាសាទ |
| 96 | អង្គនៃ | ទួល |

**សម្គាល់** ៖ វត្តក្នុងបញ្ជីនេះ គឺជា វត្តដែលបានសង់នៅលើទីតាំងបុរាណវិទ្យា ឬទីតាំងដែលមានប្រាសាទបុរាណ ។

បញ្ចប់បញ្ជីឈ្មោះប្រាសាទបុរាណ-រមណីយដ្ឋានបុរាណវិទ្យា-បុរេប្រវត្តិវិទ្យា ត្រឹម៩៦ (កៅសិបប្រាំមួយ) កន្លែង ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៨

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

**ទើខ-សិរីវុឌ្ឍ**